# ឧបសម្ព័ន្ធទី ១
# ទម្រង់លិខិតស្នើសុំ សម្រាប់ការស្នើសុំលិខិតអនុញ្ញាតផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមហ៊ុន..........
លេខ៖...............

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កម្មវត្ថុ៖** សំណើសុំលិខិតអនុញ្ញាតសម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/យើងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា (ឈ្មោះក្រុមហ៊ុនស្នើសុំ) មានបំណងផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនដល់អ្នកប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមប្រកាសស្តីពីគោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា ដែលចេញដោយក្រសួងរ៉ែ និងថាមពល កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣។ (ឈ្មោះក្រុមហ៊ុនស្នើសុំ) សូមគោរពស្នើសុំលិខិតអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល សម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជា។

សូមជូនភ្ជាប់មកជាមួយនូវឯកសារសម្រាប់ស្នើសុំលិខិតអនុញ្ញាត សម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា ដូចខាងក្រោម៖

១.ព័ត៌មានលម្អិតរបស់អ្នកស្នើសុំ
២.បទពិសោធន៍អ្នកស្នើសុំ
៣.ព័ត៌មានលម្អិតរបស់បុគ្គលិកជំនាញបម្រើការនៅក្នុងក្រុមហ៊ុនអ្នកស្នើសុំ
៤.ឯកសារភ្ជាប់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចចេញលិខិតអនុញ្ញាតឱ្យ (ឈ្មោះក្រុមហ៊ុនស្នើសុំ) ធ្វើជាអ្នកផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ ខែ ឆ្នាំ....... .......ស័ក ព.ស.២៥៦...
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២...
ប្រធាន ឬ នាយកក្រុមហ៊ុន
(ហត្ថលេខា និងត្រា)